# តុលាការអន្តរជាតិ ឬតុលាការជាតិ?

ថ្ងៃទី២៩ មិនា ឆ្នាំ២០១១

ដោយ ឆាល៍ ចេកសាន់

ប្រែសម្រួលដោយ ទែន សុខស្រីនិត

ថ្ងៃទីពីរនៃបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ កាំង ហ្គេកអ៊ាវ (ហៅ ឌុច) នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលបានផ្តោតលើបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងដោយផ្អែកលើមូលដ្ឋានផ្នែកច្បាប់ថាអង្គជំនុំជម្រះសាលាដំបូងបានបកស្រាយឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិខុស ហើយសម្រេចកាត់ទោសស្រាលពេកដល់ជនជាប់ចោទ ។ ស្របពេលដែលមានការផ្លាស់ប្តូរប្រធានបទដេញដោលនេះ ក៏មានការផ្លាស់ប្តូរវិធីសាស្ត្រដោយសហព្រះរាជអាជ្ញា អេនទ្រូ ខេលី បានប្រើប្រាស់វិធីសាស្ត្រស្ងប់ស្ងៀមដែលខុសពីវិធីសាស្ត្រកាលពីម្សិលមិញរបស់មេធាវីការពារក្តី ការ សាវុត្ថ ដែលបានធ្វើបទបង្ហាញដោយប្រើវោហាស័ព្ទធ្ងន់ៗ ។

ចៅក្រម អេកញ៉ើស្កា កូណូរីកកា មីឡាត បានចាប់ផ្តើមដំណើរនីតិវិធីដោយអានបណ្តឹងឧទ្ធរណ៍របស់ភាគីព្រះរាជអាជ្ញានិងភាគីដើមបណ្តឹងរដ្ឋប្បវេណីលើសាលក្រម ។ ព្រះរាជអាជ្ញាបានសំណូមពរឲ្យមានការវិនិច្ឆ័យទោសពីបទចោទប្រកាន់លើនិងបន្ថែមទោសឲ្យ ឌុច ម្តងទៀត ចំណែកឯមេធាវីការពារក្តីទាមទារឲ្យមានការបន្ធូរបន្ថយទោស ។

ការលើកឡើងពីអំណះអំណាងផ្នែកច្បាប់ឲ្យជាក់លាក់គឺជាវិធីសាស្ត្រខុសប្លែកគ្នាដែលព្រះរាជអាជ្ញានិងមេធាវីការពារក្តីបានប្រើប្រាស់ ។ ជាក់ស្តែង លោកព្រះរាជអាជ្ញា អេន ឌ្រូខេលី បានលើកឡើងពីអំណះអំណាងដោយសំណូមពរឲ្យអង្គជំនុំជម្រះតុលាការកំពូលឈរលើគោលជំហររបស់ខ្លួនក្នុងនាមជាតុលាការអន្តរជាតិដែលមានប្រព័ន្ធច្បាប់ខុសគ្នាពីច្បាប់កម្ពុជា ។ លោកបានស្នើសុំឲ្យតុលាការចាប់យកឳកាសដ៏សំខាន់នេះដើម្បីលើកកម្ពស់យុត្តិសាស្ត្រអន្តរជាតិផ្នែកច្បាប់ដោយសម្លឹងមើលវិធីសាស្ត្រគំរូរបស់តុលាការផ្សេងទៀត ។ គោលការណ៍នេះពិតជាមានសារៈសំខាន់ដោយសារការអះអាងនីមួយៗរបស់ព្រះរាជអាជ្ញាមានសេចក្តីអំណះអំណាងពីច្បាប់ករណីអន្តរជាតិ ។ ចំណែកឯមេធាវីការពារក៏បានរំឮកអង្គជំនុំជម្រះភ្លាមៗពេញមួយពេលថា សាលាក្តីខ្មែរក្រហមកើតឡើងនៅក្នុងប្រព័ន្ធច្បាប់កម្ពុជាដូច្នេះអង្គជំនុំជម្រះគួរតែគោរពទៅតាមច្បាប់កម្ពុជាដែរ ។

## ការចោទប្រកាន់បន្ថែមសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

មូលដ្ឋានផ្នែកច្បាប់ដំបូងសម្រាប់បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាគឺទាក់ទងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដើម្បីរាប់បញ្ចូលបទចោទប្រកាន់ទាំងអស់ទៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលក្នុងនោះរួមមាន អំពើឃាតកម្ម ការធ្វើទារុណកម្ម ការរំលោភផ្លូវភេទ និងការធ្វើពលកម្មទាំងបន្ទុំដែលទាំងអស់នេះស្ថិតនៅក្រោមឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញ ។ ដោយបង្ហាញពីការព្រួយបារម្ភសម្រាប់ការផ្សះផ្សាជាតិនិងកំណត់ត្រាជាប្រវត្តិសាស្ត្រដោយសាលាក្តីខ្មែរក្រហម លោក អេន ឌ្រូ ខេលី បានជំរុញឲ្យអង្គជំនុំជម្រះតុលាការកំពូល បែងចែកបទល្មើសនីមួយៗនេះជាឧក្រិដ្ឋកម្មដាច់ដោយឡែកពីគ្នា ។ លោកបានបញ្ជាក់ថា ការមិនបែងចែកឧក្រិដ្ឋកម្មនេះអាចនឹងធ្វើឲ្យទម្ងន់នៃបទឧក្រិដ្ឋរបស់ ឌុច មានកម្រិតស្រាល ហើយអាចនឹងធ្វើឲ្យក្មេងជំនាន់ក្រោយយល់ខុសចំពោះអ្វីដែល ឌុច បានធ្វើមកលើប្រជាជនកម្ពុជា ។

លោក អេន ឌ្រូខេលី បានគាំទ្រអំណះអំណាងគោលការណ៍របស់ខ្លួនដោយ ដកស្រង់ច្បាប់ករណីពីតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីនិងសម្រាប់រ៉្វាន់ដា ។ លោកបានអះអាងថាយុត្តិសាស្ត្រអន្តរជាតិផ្តល់ជាបទចោទប្រកាន់ព្រហ្មទណ្ឌទ្វេដងសម្រាប់ឧក្រិដ្ឋកម្មដូចគ្នាឲ្យតែបទល្មើសនីមួយៗមានឯកសារដែលទាមទារឲ្យមានភ័ស្តុតាងបញ្ជាក់លើបទល្មើសនោះមិនមែនបទល្មើសផ្សេងទៀតនោះ ។ លោកបានពន្យល់បកស្រាយពីហេតុផលដែលករណីនេះមានជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មរបស់ ឌុច ជាឧទាហរណ៍ ដោយធ្វើការប្រៀបធៀប ពីការធ្វើទុក្ខបុកម្នេញ និង អំពើមនុស្សឃាត ។ អំពើមនុស្សឃាតតម្រូវឲ្យមានភ័ស្តុតាងដែលថា ជនជាប់ចោទបានបង្កឲ្យមានការសម្លាប់មនុស្សខុសពីការធ្វើទុក្ខបុកម្នេញដែលមិនតម្រូវឲ្យមានភស្តុតាងដូច្នេះទេ ។ ចំណែកការធ្វើទុក្ខបុកម្នេញ តម្រូវឲ្យមានការបង្ហាញឲ្យឃើញពីចេតនារើសអើងដែលផ្ទុយពីអំពើឃាតកម្ម ។

មេធាវីការពារក្តីមិនបានធ្វើការឆ្លើយតបអ្វីឡើយ ។

## ការរំលោភផ្លូវភេទជាបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

បន្ទាប់មកទៀត សហព្រះរាជអាជ្ញាបានលើកឡើងពីអំណះអំណាងរបស់ខ្លួនស្តីពីមូលហេតុដែលអង្គជំនុំជម្រះសាលាដំបូងបានយល់ខុសដោយចាត់ទុកការរំលោភផ្លូវភេទជាផ្នែកមួយនៃការធ្វើទារុណកម្មដោយមិនទទួលស្គាល់ថាការរំលោភផ្លូវភេទនេះគឺជាឧក្រិដ្ឋកម្មដាច់ដោយឡែកមួយនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទៅវិញ ។ លោកសហព្រះរាជអាជ្ញា អេន ឌ្រូខេលី បានរៀបរាប់ពីប្រវត្តិនៃការរំលោភផ្លូវភេទ ថាជាបទល្មើសដែលទទួលស្គាល់ដោយប្រទេសស៊ីវិលដូចជាក្រម លីប៊ឺ ឆ្នាំ១៩៦៣ ស្តីពីសង្គ្រាមស៊ីវិល របស់អាមេរិច ហើយរួមមានការដកស្រង់ចេញពីរដ្ឋធម្មនុញ្ញទីក្រុង ហាហ្គ, រដ្ឋ

ធម្មនុញ្ញ ទីក្រុងហ្សឺណែវ និងច្បាប់លេខ១០នៃច្បាប់ក្រុមប្រឹក្សាគ្រប់គ្រង ឆ្នាំ១៩៤៥ ។ លោកបានបញ្ជាក់ថាចាប់តាំងពីឆ្នាំ១៩៤៥មក ការរំលោភផ្លូវភេទត្រូវចាត់ទុកយ៉ាងច្បាស់លាស់ថាជាឧក្រិដ្ឋកម្មមួយដែលឋិតនៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដូច្នេះការចោទប្រកាន់ ឌុច ពីបទរំលោភផ្លូវភេទថាជាបទល្មើសមួយដែលខុសពីការធ្វើទារុណកម្មមិនបានរំលោភបំពានលើគោលការណ៍ច្បាប់ឡើយ ។ លោកបានលើកអំណះអំណាងមកគាំទ្រសេចក្ដីអះអាងរបស់ព្រះរាជអាជ្ញាដោយដកស្រង់ឯកសារយោងជាច្រើនចេញពីតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី,តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ៉្វាន់ដានិងតុលាការពិសេសសម្រាប់សៀរ៉ា ឡេអូន ដែលតុលាការទាំងអស់នេះបានចាត់ទុកការរំលោភផ្លូវភេទជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។

លោក អេន ខ្លូខេលី បានបកស្រាយថាគោលការណ៍ផ្នែកច្បាប់ មិនតម្រូវឲ្យបទល្មើសចង់ក្រងជាច្បាប់មុនពេលនៃការប្រព្រឹត្តឧក្រិដ្ឋកម្មនេះឡើយ ។ ផ្ទុយទៅវិញ គោលការណ៍ផ្នែកច្បាប់ត្រូវបានបំពេញលក្ខខ័ណ្ឌរបស់ខ្លួន នៅពេលដែលជនដៃដល់បានដឹងជាមុនថាការប្រព្រឹត្តរបស់ខ្លួនគឺមានទោស ។ លោក អេន ខ្លូខេលី បានអះអាងថាភ័ស្តុតាងនិងកំណត់ត្រាជាប្រវត្តិសាស្ត្របានគូសបញ្ជាក់យ៉ាងច្បាស់លាស់ថា ឌុច បានដឹងថាការរំលោភផ្លូវភេទនៅមន្ទីរស-២១គឺជាបទល្មើស ។

លោក កង ឫទ្ធារី សហមេធាវីការពារក្ដីបានឆ្លើយតបទៅនឹងការអះអាងរបស់ព្រះរាជអាជ្ញាវិញដោយក្រើនរំឭកតុលាការថាតុលាការមិនមានយុត្តាធិការក្នុងការកាត់ទោស ឌុច ទេ ។ លោកបានជំទាស់ថា ឌុច មិនគួរត្រូវបានកាត់ទោសឲ្យទទួលខុសត្រូវសម្រាប់អំពើរំលោភផ្លូវភេទដែលបានកើតឡើងនៅមន្ទីរស-២១ទេ ពីព្រោះថា ឌុច បានដាក់ទណ្ឌកម្មជនដៃដល់ ហើយបានចាត់វិធានការភ្លាមៗដើម្បីការពារកុំឲ្យមានករណីរំលោភផ្លូវភេទនេះកើតឡើងនាពេលអនាគត ។ បន្ទាប់មក លោក ការ សាវុត្ថ បានធ្វើសេចក្ដីសន្និដ្ឋានដ៏សង្ខេបថា ដោយសារតែការខ្វះខាតនូវមូលដ្ឋានផ្នែកច្បាប់ ការរំលោភផ្លូវភេទនៅមន្ទីរស-២១មិនអាចចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិបានទេ ពីព្រោះករណីនេះបានកើតឡើងតែម្ដងគត់ ដូច្នេះវាមិនអាចចាត់ទុកថាជាឧក្រិដ្ឋកម្មជាលក្ខណៈប្រព័ន្ធនិងទ្រង់ទ្រាយធំបានឡើយ ។

## ការដាក់ជាទាសករ និងការធ្វើពលកម្មទាំងបង្ខំ

ចុងក្រោយបង្អស់ ព្រះរាជអាជ្ញាបានអះអាងថាអង្គជំនុំជម្រះសាលាដំបូងបានមានកំហុសឆ្គងដោយដាក់បញ្ចូលការធ្វើពលកម្មទាំងបង្ខំទៅក្នុងនិយមន័យនៃការដាក់ជាទាសករ ។ លោក អេន ខ្លូខេលី បានបញ្ជាក់ថាកំហុសឆ្គងនេះបានបណ្ដាលឲ្យអង្គជំនុំជម្រះសាលាដំបូងមិនធ្វើការចោទប្រកាន់ ឌុច ពីបទប្រព្រឹត្តជាច្រើនទៀតនៃការដាក់ជាទាសករនៅឯមន្ទីរស-២១ ។ នៅក្នុងសាលក្រមសំណុំរឿង ០០១អង្គជំនុំជម្រះសាលាដំបូងបានចោទប្រកាន់ ឌុច ពីបទការដាក់ជាទាសករលើអ្នកទោសទាំងអស់

នៅមន្ទីរស-២៤(ទីកន្លែងធ្វើពលកម្មរបស់មន្ទីរស២១) និងអ្នកទោសនៅមន្ទីរស-២១ ទាំងអស់ដែលត្រូវបានបង្ខំឲ្យធ្វើពលកម្ម ។ លោក អេន ឡូខេលី បានជំរុញឲ្យអង្គជំនុំជម្រះតុលាការកំពូលធ្វើការកំណត់ឡើងវិញលើ និយមន័យ និងការចោទប្រកាន់ ឌុច របស់អង្គជំនុំជម្រះសាលាដំបូងពីបទការដាក់ជាទាសករមកលើអ្នកទោសទាំងអស់នៅមន្ទីរស-២១ ។

លោក ឫទ្ធារី មេធាវីការពារក្តីបានឆ្លើយតបយ៉ាងសង្ខេបទៅវិញដោយបដិសេធនឹងការអះអាងខាងលើដែលថាការដាក់ជាទាសករ និងការធ្វើពលកម្មទាំងបង្ខំបានកើតឡើង ។ លោកបាននិយាយថាអ្នកទោសអាច "ដើរដោយសេរី" និងត្រូវបានទទួលរងការប្រព្រឹត្តដោយស្មើភាពគ្នាទៅនឹងកម្មាភិបាលខ្មែរក្រហម ។ "បើទោះបីជាអ្នកទោសមន្ទីរស-២១ និងស-២៤ត្រូវបានឃុំខ្លួនក៏ដោយ ក៏អ្នកទោសនោះអាចទៅធ្វើការងារបាន ។ សូម្បីតែកម្មាភិបាលខ្មែរក្រហមក៏ទទួលរងការបង្ខិតបង្ខំរាំងខ្លះៗដែរ" ។

## ការស្នើទោស

សហព្រះរាជអាជ្ញាបានអះអាងថាកំហុសឆ្គងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបណ្តាលឲ្យមានការផ្តន្ទាទោសដែល"មានកម្រិតមិនធ្ងន់ធ្ងរគ្រប់គ្រាន់" ដូច្នេះព្រះរាជអាជ្ញាស្នើសុំឲ្យអង្គជំនុំជម្រះសាលាកំពូលបង្កើតទោសនេះពី៣៥ឆ្នាំមកការជាប់ទោសអស់មួយជីវិត ។ យ៉ាងណាមិញព្រះរាជអាជ្ញាក៏បានទទួលស្គាល់ថាការរំលោភបំពានផ្លូវច្បាប់លើរយៈពេលឃុំខ្លួន ឌុច នៅមន្ទីរឃុំឃាំងយោធាដោយខុសច្បាប់ពិតជាតម្រូវឲ្យមានការកាត់បន្ថយទោសរយៈពេល៥ឆ្នាំ ។ ដូច្នេះ ការស្នើសុំចុងក្រោយពីសំណាក់ការិយាល័យសហព្រះរាជអាជ្ញាគឺការដាក់ទោស ឌុច ឲ្យជាប់ពន្ធនាគាររយៈពេល៤៥ឆ្នាំដោយគ្មានការដោះលែងមុនកាលកំណត់ឡើយ ។

មេធាវីការពារក្តីបានបញ្ចេញទស្សនៈខុសពីនេះដោយជំរុញឲ្យអង្គជំនុំជម្រះសាលាកំពូលឲ្យសម្រេចថាអង្គជំនុំជម្រះសាលាដំបូងមិនបានពិចារណាលើកត្តាសម្រាលទោសឲ្យបានគ្រប់គ្រាន់នៅឡើយទេដែលក្នុងនោះរួមមានការសហការ និងការសម្តែងវិប្បដិសារីរបស់ ឌុច ។ សហមេធាវីការពារក្តី កង ឫទ្ធារី បានបរិយាយយ៉ាងក្បោះក្បាយថា ឌុច ជាបុរសម្នាក់ដែលហ៊ានធ្វើអ្វីៗគ្រប់យ៉ាងដែលខ្លួនអាចធ្វើបានដើម្បីទប់ស្កាត់គ្រោះថ្នាក់ដែលបណ្តាលមកពីការប្រព្រឹត្តដែល ឌុច ត្រូវបានបង្ខំឲ្យធ្វើដោយការខ្លាចស្លាប់ ។ លោក ឫទ្ធារី បានជំរុញឲ្យចៅក្រមធ្វើការពិចារណាថា តើចៅក្រមធ្វើយ៉ាងដូចម្តេចដែលប្រសិនបើជីវិតរបស់ចៅក្រមត្រូវបានខ្មែរក្រហមគំរាមកំហែង ហើយលោកបាន ឆ្លើយប្រាប់ចៅក្រមទៅវិញថា "អ្នកទាំងអស់គ្នាអាចនឹងអង្គុយនៅកន្លែងដែល ឌុច កំពុងតែអង្គុយថ្ងៃនេះ" ។

មេធាវីការពារក្តីបានស្នើសុំថាប្រសិនបើអង្គជំនុំជម្រះសាលាកំពូលមិនសម្រេចដោះលែង ឌុច ពីព្រោះអង្គជំនុំជម្រះមិនមានយុត្តាធិការគ្រប់គ្រាន់សម្រាប់កាត់ទោស ឌុច ទេនោះ យ៉ាងហោចណាស់ចៅក្រមសាលាកំពូលគួរតែកាត់បន្ថយទោសឲ្យ ឌុច ត្រឹម១៥ឆ្នាំ ។ បើពិចារណាលើកត្តាសម្រាល

ទោសសម្រាប់ការរំលោភផ្លូវច្បាប់ និងរយៈពេលឃុំខ្លួន ឌុច ដោយខុសច្បាប់នោះ ជាសរុបទោសជាប់ពន្ធនាគាររយៈពេល១៥ឆ្នាំនេះអាចដោះលែង ឌុច ចេញពីមន្ទីរឃុំឃាំងភ្លាមតែម្តង ។

## តុលាការជាតិ ឬ អន្តរជាតិ?

ការពឹងផ្អែកយ៉ាងខ្លាំងក្លារបស់ព្រះរាជអាជ្ញាលើច្បាប់អន្តរជាតិ និងគោលជំហររបស់មេធាវីការពារក្តីដែលថាសាលាក្តីខ្មែរក្រហមគឺជាតុលាការជាតិនោះបានបណ្តាលឲ្យមានការជជែកដេញដោលគ្នាយ៉ាងតានតឹងនាពេលរសៀលនេះខណៈពេលដែលភាគីទាំងពីរបានជជែកដេញដោលគ្នាថាតើអង្គជំនុំជម្រះសាលាកំពូលគួរតែពិចារណាក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩នៅពេលដែលចៅក្រមសម្រេចទោសដ៏សមរម្យឲ្យដួច ។ មាត្រា៩៥នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ចែងថាប្រសិនបើការកាត់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិតត្រូវបានសម្រាលទោសដោយសារកត្តាសម្រាលទោសនោះចៅក្រម "អាចនឹងដាក់ទោសជន់ជាប់ចោទឲ្យជាប់ទោសក្នុងចន្លោះពេលពី១៥ឆ្នាំទៅ៣០ឆ្នាំ" ។ ប៉ុន្តែមាត្រា៦៨៨នៃក្រមព្រហ្មទណ្ឌដដែលនេះក៏ចែងថាក្រមនេះនឹងមិនត្រូវបានយកមកអនុវត្តនោះទេប្រសិនបើក្រមព្រហ្មទណ្ឌនេះមានលក្ខណៈចម្រូងចម្រាសជាមួយនឹង "ច្បាប់ព្រហ្មទណ្ឌពិសេស" ផ្សេងទៀត ។

មេធាវីការពារក្តីបានតវ៉ាថាក្នុងសមាសធាតុជាតុលាការជាតិសាលាក្តីខ្មែរក្រហមត្រូវតែគោរពទៅតាមមាត្រា៩៥ ដូច្នេះ សាលាក្តីខ្មែរក្រហមគួរតែផ្តន្ទាទោសជនជាប់ចោទខ្ពស់បំផុតគឺរយៈពេល៣០ឆ្នាំដែលអាច ប្រឆាំងតវ៉ាបានយោងតាមកត្តាសម្រាលទោសសម្រាប់សំណុំរឿងរបស់ ឌុច ។ មេធាវីការពារក្តីបានអះអាងថា បើទោះបីជាការរៀបរៀងលក្ខន្តិកៈរបស់សាលាក្តីខ្មែរក្រហមត្រូវបានព្រាងមុននឹងសាលាក្តីខ្មែរក្រហមបានកកើតឡើងក៏ដោយការរៀបរៀងលក្ខន្តិកៈនេះតម្រូវឲ្យជនជាប់ចោទទទួលបានប្រយោជន៍ពីច្បាប់ព្រហ្មទណ្ឌដែលត្រូវបានតាក់តែងឡើងក្រោយពីការប្រព្រឹត្តនៃឧក្រិដ្ឋកម្មដដែល ។

ប៉ុន្តែ ព្រះរាជអាជ្ញាបានអះអាងថា ច្បាប់សាលាក្តីខ្មែរក្រហមមានលក្ខណៈស្របទៅនឹង "ច្បាប់ព្រហ្មទណ្ឌពិសេស" ផ្សេងទៀតដូច្នេះសាលាក្តីខ្មែរក្រហមមិនតម្រូវឲ្យគោរពតាមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ឡើយ ។ ផ្ទុយទៅវិញ សាលាក្តីខ្មែរក្រហមត្រូវតែគោរពតាមមាត្រា៣៩នៃច្បាប់បង្កើតសាលាក្តីខ្មែរក្រហមដែលអនុញ្ញាតឲ្យចៅក្រមពង្រីកសិទ្ធិអំណាចរបស់ខ្លួនដែលអាចដាក់ទោសជនជាប់ចោទក្នុងចន្លោះរយៈពេលពី៥ឆ្នាំទៅជាប់ទោសអស់មួយជីវិត ។

ចៅក្រម ក្លូវីកកា មីឡាត បានធ្វើឲ្យអ្នកតាមដានអង្គសវនាមានភាពច្របូកច្របល់នៅពេលដែលលោកស្រីចៅក្រមបានបដិសេធចោលគោលជំហររបស់ព្រះរាជអាជ្ញាដែលចាត់ទុកសាលាក្តីខ្មែរក្រហមជាតុលាការប្លែកដោយឡែកមួយដែលមិនតម្រូវឲ្យគោរពតាមគោលការណ៍ច្បាប់ក្នុងស្រុក ។ លោកស្រីចៅក្រមក៏បានបង្ហាញពីចម្ងល់របស់លោកស្រីថា តើមាត្រា៩៥នៃក្រមព្រហ្មទណ្ឌ

កម្ពុជាឆ្នាំ២០០៩មានភាពចម្រូងចម្រាសនឹងច្បាប់សាលាក្តីខ្មែរក្រហម មែនដែរឬទេ ដោយបង្ហាញការជឿជាក់របស់លោកស្រីថាមាត្រា៦៦៨នៃច្បាប់ព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩មានជាប់ពាក់ព័ន្ធអ្វីឡើយ ។ បន្ទាប់មកទៀត លោកស្រីចៅក្រមបានចោទសួរភាគីព្រះរាជអាជ្ញាថាក្នុងសមាសធាតុជាតុលាការជាតិ ប្រសិនបើតុលាការយកក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ដែលជាច្បាប់កម្ពុជាមកពិចារណានោះតើតុលាការនឹងមិនបម្រើប្រយោជន៍ដល់ប្រជាជនកម្ពុជាយ៉ាងដូចម្តេចខ្លះ ។ ព្រះរាជអាជ្ញាបានគូសបញ្ជាក់ពីគោលជំហររបស់ខ្លួនម្តងទៀតថា តុលាការនេះ គឺជាតុលាការប្លែកពីគេ ហើយបើទោះបីជាតុលាការនេះត្រូវបានចាត់ទុកជាតុលាការជាតិក៏ដោយក៏តុលាការនេះនឹងនៅតែឋិតនៅក្រោមអញ្ញត្រកម្មមាត្រា៦៦៨ដដែល ។ ចៅក្រមក្លូណូវីកកា មីឡាត ទំនងជាមិនជឿជាក់លើសម្តីរបស់ព្រះរាជអាជ្ញាប៉ុន្មានទេ ។ ជាលទ្ធផល ដោយដឹងពីផលប៉ះពាល់នៃការសួរដេញដោលពីចៅក្រមសាលាកំពូលលើការដាក់ទោស ឌុច អ្នកតាមដានម្នាក់បានដើរចេញពីបន្ទប់សវនាការទាំងទឹកភ្នែក ។